**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៥៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរសិទ្ធិគ្រប់គ្រងចំការកៅស៊ូ ក្រែក

## រាជរដ្ឋាភិបាល

-បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញព្រះរាជក្រមលេខ នស/រកម/ ០៦៩៥/០៤ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី វិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រមលេខ ជស/រកម/ ០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពី ការអនុវត្តន៍ព្រះរាជក្រម ស្តីពី លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញអនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ២០០៣ ស្តីពីការបង្កើតគណៈកម្មាធិការជាតិអវិនិយោគរបស់រដ្ឋ , លើសហគ្រាសចំការកៅស៊ូ ក្រុមហ៊ុនសំភារៈកសិកម្ម និង ក្រុមហ៊ុនជលផល

-បានឃើញកិច្ចសន្យាទិញ-លក់ និង កិច្ចសន្យាជួលដីចំការកៅស៊ូក្រែក ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៨ រវាងរាជរដ្ឋាភិបាលកម្ពុជា និង ក្រុមហ៊ុនប្រស្តេរិធី អេហ្គ្រីខលឈ័រ

-តាមសំណើរបស់គណៈកម្មាធិការជាតិអវិនិយោគរបស់រដ្ឋ លើសហគ្រាសចំការកៅស៊ូ ក្រុមហ៊ុនសំភារៈកសិកម្ម និង ក្រុមហ៊ុនជលផល

# ស ម្រេ ច

**មាត្រា១:** បញ្ចប់ស្ថានភាពគតិយុត្តិចំការកៅស៊ូក្រែក ដែលជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច ចាប់ពីថ្ងៃ ទី ១០ ខែ តុលា ឆ្នាំ ២០០៨ តទៅ។

**មាត្រា២:** ផ្ទេរសិទ្ធិគ្រប់គ្រងចំការកៅស៊ូក្រែកទៅឱ្យក្រុមហ៊ុន ប្រស្ពើរិធី អេហ្គ្រីខលឈ័រ (PROSPERITY AGRICULTURE Co.,Ltd.) ដើម្បីបន្តគ្រប់គ្រងស្របតាមបទប្បញ្ញត្តិនានាដែលបានកំណត់ក្នុងកិច្ចសន្យាទិញ-លក់ និង កិច្ចសន្យាជួលដីចំការកៅស៊ូក្រែក ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៨ រវាងរាជរដ្ឋាភិបាលកម្ពុជា និង ក្រុមហ៊ុន ប្រស្ពើរិធី អេហ្គ្រីខលឈ័រ (PROSPERITY AGRICULTURE Co.,Ltd.) ចាប់ពីថ្ងៃ ទី ១០ ខែ តុលា ឆ្នាំ ២០០៨ តទៅ។

**មាត្រា៣:** រំលាយក្រុមប្រឹក្សាភិបាលប្រចាំចំការកៅស៊ូក្រែក រំលាយប្រធានអគ្គនាយកចំការកៅស៊ូក្រែក និង រំលាយមន្ត្រីត្រួតពិនិត្យរដ្ឋអមចំការកៅស៊ូក្រែក ចាប់ពីថ្ងៃ ទី ១០ ខែ តុលា ឆ្នាំ ២០០៨ តទៅ។

**មាត្រា៤:** ផ្ទេរឯកឧត្តម សៀក ពិសិដ្ឋ ប្រធានអគ្គនាយកចំការកៅស៊ូក្រែក ចូលមកបំរើការងារក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទវិញ ចាប់ពីថ្ងៃ ទី ១០ ខែ តុលា ឆ្នាំ ២០០៨ តទៅ។

**មាត្រា៥:** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវទទួលបន្ទុកដោះស្រាយបន្តរាល់បំណុលត្រូវទារ និង ត្រូវសង ដែលនៅសេសសល់ទាំងអស់ រវាងចំការកៅស៊ូក្រែក និង បណ្តាក្រុមហ៊ុន ស្ថាប័ននានានិងអតិថិជន ។

**មាត្រា៦:** ចំការកៅស៊ូក្រែក ត្រូវប្រគល់ត្រានិងឯកសារពាក់ព័ន្ធទាំងអស់ រួមទាំងឯកសារក្នុងកុំព្យូទ័រ មកក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដើម្បីរក្សាទុក។

**មាត្រា៧:** ថវិកាដែលនៅសល់ក្នុងគណនី និង បេឡា របស់ចំការកៅស៊ូក្រែក ត្រូវផ្ទេរចូលថវិកាជាតិ។

បិទរាល់គណនីធនាគារទាំងអស់របស់ចំការកៅស៊ូក្រែក ចាប់ពីថ្ងៃ ទី ១០ ខែ តុលា ឆ្នាំ ២០០៨ តទៅ។

**មាត្រា៨:** អនុក្រឹត្យលេខ ១៥ អនក្រ-បក ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពី ការបង្កើតចំការកៅស៊ូ ក្រែក ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច និង បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ចាប់ពីថ្ងៃ ទី ១០ ខែ តុលា ឆ្នាំ ២០០៨ តទៅ។

**មាត្រា៩:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះតាមភារកិច្ច រៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ ១០ ឆ្នាំ ២០០៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- - ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- - ដូចមានក្នុងមាត្រា ៩
- - រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ